*សុវត្ថិភាពសម្រាប់ភ្ញៀវ សុវត្ថិភាពសម្រាប់កម្មករ សុវត្ថិភាពសម្រាប់គ្រប់គ្នា*

# សណ្ឋាគារនិងកាស៊ីណូមានសុវត្ថិភាព

## ធានាថាសណ្ឋាគារមានសុវត្ថិភាពសម្រាប់ភ្ញៀវនិងកម្មករនៅក្នុងសម័យកូវីដ-១៩

បណ្ឌិត ហ៊ីឌីយ៉ាត ហ្រ្គីនហ្វៀល
លេខាធិការប្រចាំតំបន់អាស៊ី/ប៉ាស៊ីហ្វិក IUF
១១ ឧសភា ២០២០

វិស័យទេសចរណ៍ នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ត្រូវបានទទួលរកការវាយប្រហារយ៉ាងខ្លាំងក្លា ដោយសារតែការរាតត្បាតកូវីដ-១៩ ជាពិសេសនៅក្នុងឧស្សាហកម្មសណ្ឋាគារនិងរីសត។ ការលុបចោលជើងហោះហើរ ការរឹតត្បឹតទៅលើការធ្វើដំណើរជាអន្តរជាតិ និងការបិទស្ទើរទាំងស្រុង នៅប្រទេសភាគច្រើន បានធ្វើឲ្យមានអាត្រានៃការស្នាក់នៅ ស្ថិតនៅក្នុងកម្រិតសូន្យ ហើយការបិទបណ្ដោះអាសន្ននៃសណ្ឋាគារនិងរីសតភាគច្រើន មានរយៈពេលពីបីទៅប្រាំមួយខែ។

វានឹងត្រូវការពេលវេលាច្រើនខែទៀតដើម្បីឲ្យឧស្សាហកម្មនេះ ងើបឡើងវិញដូចដើម។ ភាគច្រើន ត្រូវពឹងផ្អែកទៅលើការត្រឡប់ទៅរកភាពធម្មតាវិញ នៃទេសចរណ៍ក្នុងស្រុកនិងព្រឹត្តិការណ៍នានានៅក្នុងស្រុក (ដូចជា ការរៀបអាពាហ៍ពិពាហ៍ ការជប់លៀង និងសន្និសីទ) ហើយបន្ទាប់មក គឺការវិលត្រឡប់មករកសភាពធម្មតាវិញជាបន្តបន្ទាប់នៃទេសចរណ៍និងការធ្វើដំណើរអន្តរជាតិ។

គ្មានអ្វីដែលត្រូវសង្ស័យទេថា ការវិលត្រឡប់ទៅរកសភាពធម្មតាវិញ នឹងត្រូវការពេលវេលា។ វានឹងមានបញ្ហាប្រឈមខ្លាំង។ បញ្ហប្រឈមសំខាន់បំផុតមួយក្នុងចំណោមបញ្ហាប្រឈមនានានោះ គឺការត្រឡប់ទៅរកសភាពធម្មតាវិញនៃទំនុកចិត្តនិងភាពជឿជាក់របស់មនុស្ស ក្នុងការធ្វើដំណើរម្តងទៀត និងសម្រាប់ភ្ញៀវដែលត្រូវត្រឡប់ទៅស្នាក់នៅក្នុងសណ្ឋាគារវិញ។ ទំនុកចិត្តនិងភាពជឿជាក់នេះ ត្រូវអាស្រ័យទៅលើថាតើអ្នកធ្វើដំណើរនិងភ្ញៀវ អាចទទួលបានការធានាថាសណ្ឋាគារ រីសតកាស៊ីណូទាំងនោះ មាន*សុវត្ថិភាព* ឬទេ។

យើងទាំងអស់គ្នាបានឮថា ការរាតត្បាតកូវីដ-១៩ និងផលប៉ះពាល់របស់វា ត្រូវបានគេពណ៌នាថា ជារឿងដែលមិនធ្លាប់កើតមានពីមុនមក។ ជាការពិតគ្មានមន្ទិលអ្វីឡើយ ដែលថា គ្រប់យ៉ាងបានផ្លាស់ប្តូរនៅក្នុងសម័យកូវីដ-១៩។ នេះក៏មានន័យដែរថា វិស័យសណ្ឋាគារនិងទេសចរណ៍ មិនអាចឆ្លើយតបតាមរយៈការផ្សព្វផ្សាយលើកកម្ពស់

ម៉ាកយីហោនិងការធ្វើការផ្សព្វផ្សាយពាណិជ្ជកម្មដដែលៗ ដូចដែលពួកគេបានប្រើប្រាស់ជាធម្មតាពីមុននោះទេ។ មនុស្សមិនចង់បានរូបភាពនៃសុវត្ថិភាពទេ។ មនុស្សត្រូវការចង់ដឹង ថាតើសណ្ឋាគារណាមួយឬកាស៊ីណូណាមួយនោះ *ពិតជាមានសុវត្ថិភាពមែនឬទេ*។

វិធីតែមួយគត់ដើម្បីធានាថាសណ្ឋាគារឬរីសតសណ្ឋាគារកាស៊ីណូមានសុវត្ថិភាពនោះ គឺត្រូវបង្កើតនិងអនុវត្ត*សេចក្តីណែនាំទូលំទូលាយស្តីពីសុខភាពនិងអនាម័យ* និង *ឲ្យមានការចូលរួមពាក់ព័ន្ធដោយផ្ទាល់ពីសហជីពរបស់ពួកគេ។*

ត្រូវចាត់វិធានការដើម្បីធានាថា គ្រប់គ្នា ទាំងថ្នាក់គ្រប់គ្រង កម្មករ និងភ្ញៀវទាំងឡាយ អនុលោមតាមសេចក្តីណែនាំទាំងនេះ។ សម្រាប់កម្មករ ការអនុលោមតាមរបៀបរបបឬសេចក្តីណែនាំណាមួយ និងការអនុវត្តប្រចាំថ្ងៃ មិនអាចពឹងផ្អែកទៅលើការដាក់ទណ្ឌកម្មនិងការគំរាមកំហែងនោះទេ។ វាត្រូវតែពឹងផ្អែកទៅលើការរៀបចំការងារឲ្យបានប្រសើរ ការបណ្តុះបណ្តាលបន្ថែម សុវត្ថិភាពការងារ (ដើម្បីឲ្យវាពិតជាមានភាពសំខាន់) និងការចូលរួមពាក់ព័ន្ធរបស់កម្មករ។

ការអនុវត្តរបៀបរបបទាក់ទងនឹងសុខភាពនិងសុវត្ថិភាព មិនអាចទុកឲ្យធ្វើឡើងតាមរយៈការប្រាស្រ័យទាក់ទងផ្នែកធនធានមនុស្សរបស់ក្រុមហ៊ុន ដែលបានកើតឡើងនៅមុនពេលកូវីដ-១៩ ទៀតទេ។ វាជាការប្រាស្រ័យទាក់ទងដែលអាចធ្វើឲ្យកម្មករសណ្ឋាគារមានការភាន់ច្រឡំ មិនប្រាកដប្រជា និងមានហានិភ័យ នៅគ្រាដំបូងនៃការរីករាតត្បាត។ ការប្រាស្រ័យទាក់ទងរបស់ក្រុមហ៊ុនដែលធ្វើឲ្យមានអារម្មណ៍ល្អនោះ បានបរាជ័យ។ វាបង្កើតភាពតានតឹងចិត្តនិងអន្ទះសារក្នុងចិត្ត។ វាធ្វើឲ្យមានហានិភ័យដល់អាយុជីវិត។ ការនិយាយថា "យើងនៅក្នុងស្ថានភាពនេះទាំងអស់គ្នា" និង "សូមផ្តល់យោបល់ត្រឡប់ឲ្យពួកយើង" (បន្ទាប់មក ដាក់ការកាត់ប្រាក់ឈ្នួល ឬការសម្រាកដោយគ្មានប្រាក់កម្រៃគ្មានពេលកំណត់) បានធ្វើឲ្យកម្មករសណ្ឋាគាររាប់សែននាក់ យល់ច្បាស់ថា ពួកគេត្រូវពឹងលើខ្លួនឯង។

ប្រសិនបើការត្រឡប់មករកសភាពធម្មតាវិញនៃឧស្សាហកម្មទេសចរណ៍ ពឹងផ្អែកទៅលើការកសាងឡើងវិញនូវជំនឿចិត្តរបស់អ្នកធ្វើដំណើរនិងភ្ញៀវនោះ វាក៏ត្រូវការស្តារឡើងវិញនូវជំនឿចិត្តខ្ទេចខ្ទាំរបស់កម្មករសណ្ឋាគារដែរ។

ដោយសារតែគ្រោះថ្នាក់ដែលអាចកើតឡើងនៅកន្លែងការងារ ដែលធ្វើឲ្យមានហានិភ័យដល់សុខភាពរបស់កម្មករនោះ វិធីសាស្ត្រដែលមានប្រសិទ្ធភាពតែមួយគត់ ក្នុងការធានាឲ្យមានកន្លែងការងារដែលមានសុវត្ថិភាពនោះ គឺការឲ្យមានការចូលរួមពាក់ព័ន្ធដោយផ្ទាល់ពីកម្មករ តាមរយៈសហជីពរបស់ពួកគេ។ តាមរយៈការចូលរួមក្នុងគណៈកម្មការសុខភាពនិងសុវត្ថភាព ដែលមានការចូលរួមពាក់ព័ន្ធពីសហជីពនិងថ្នាក់គ្រប់គ្រង និងតាមរយៈការអនុវត្ត

សេចក្តីណែនាំទូលំទូលាយស្តីពីសុខភាពនិងអនាម័យ***ជាមួយគ្នា*** នោះ សណ្ឋាគារមានសុវត្ថិភាព/កន្លែងការងារមានសុវត្ថិភាព ពិតជាអាចកើតឡើងបាន។

តាមរយៈការទទួលស្គាល់កម្មករជួរមុខ នៅក្នុងការប្រយុទ្ធប្រឆាំងនឹងការរាតត្បាតកូវីដ-១៩ នោះ យើងក៏ត្រូវទទួលស្គាល់ដែរថា ***កម្មករក្នុងសណ្ឋាគារនិងរីសត នឹងបន្តស្ថិតនៅជួរមុខនៅក្នុងសម័យកូវីដ-១៩។*** អន្តរកម្មជាបន្តជាមួយមនុស្សនៅជិតៗគ្នាក្នុងចំណោមមនុស្សកកកុញ នៅក្នុងសណ្ឋាគារ និងក្នុងរីសត មានន័យថា ជាការប្រឈមមុខជាបន្ត ទៅនឹងហានិភ័យនៃកូវីដ-១៩ នៅកន្លែងការងារ។ សណ្ឋាគារ *គឺជា* កន្លែងសាធារណៈ៖ ការហូប ការសម្រាក ការដេក ការកំសាន្ត ការជួបប្រជុំ ការធ្វើការ នៅក្នុងលំហមួយដែលបិទជិត។ កម្មករសណ្ឋាគារ ដែលកំពុងធ្វើការជាបន្តនៅក្នុងលំហនោះ ត្រូវការទៅផ្ទះជួបជុំគ្រួសាររបស់ពួក*ដោយមានសុខភាពល្អ*។

នៅក្នុងសម័យកូវីដ-១៩នេះ ទីបំផុត មាន***ការទទួលស្គាល់អំពីគុណតម្លៃការងារ*** ដែលកម្មករសណ្ឋាគារនិងរីសតកាស៊ីណូបានធ្វើ។ កិច្ចប្រឹងប្រែងបច្ចុប្បន្ននៅក្នុងសណ្ឋាគារនិងរីសត ក្នុងការប្រាប់កម្មករមិនឲ្យមកធ្វើការ ឬបង្ខំឲ្យឆាប់ចូលនិវត្តន៍នោះ គឺជារឿងមិនសមហេតុផលទាល់តែសោះ។

ទីបំផុត សណ្ឋាគារដែលមានសុវត្ថិភាព ត្រូវពឹងផ្អែកទៅលើសេវាដែលផ្តល់ដោយកម្មករជំនាញ និងមានបទពិសោធន៍ តាមរយៈការងារដែលមានសុវត្ថិភាព។ ការធ្វើឲ្យមនុស្សជំនះលើភាពភ័យខ្លាចនិងអន្ទះសារ ដើម្បីឲ្យក្លាយជាអ្នកធ្វើដំណើរនិងភ្ញៀវដែលមានទំនុកចិត្តជាថ្មីម្តងទៀតនោះ មានន័យថា ត្រូវធានាឲ្យមានគុណភាពសេវានិងសុវត្ថិភាព។ (មនុស្សរាប់សិបលាននាក់ ចំណាយពេលនៅផ្ទះ នៅក្នុងការបិទទីក្រុងឬប្រទេស។ ពួកគេមិនត្រូវការការចម្អិនអាហារនៅផ្ទៃឬបម្រើសេវាកម្មខ្លួនឯងទៀតទេ។) ជំនាញនិងបទពិសោធន៍ ពីក្រោយសេវាកម្មនេះ បង្កើតឲ្យមានជំនឿចិត្ត។ ការប្រាប់កុំឲ្យកម្មករមកធ្វើការ ឬបង្ខំឲ្យអ្នកមានបទពិសោធន៍ច្រើន ឆាប់ចូលនិវត្តន៍ ជាការបំផ្លាញជំនឿចិត្តទាំងនេះ (ជាថ្មីម្តងទៀត) ច្បាស់ណាស់។

ជាចុងក្រោយ មានការទទួលស្គាល់ថា សុខភាពនិងអនាម័យ មានសារៈសំខាន់ខ្លាំងណាស់ ក្នុងការធានាឲ្យបានសណ្ឋាគារដែលមានសុវត្ថិភាពនិងសុខភាពសាធារណៈ។ ***ការងាររបស់អ្នកសម្អាត អ្នកសម្អាតបន្ទប់ អ្នកបម្រើសេវាតាមបន្ទប់ អ្នកលាងចាន ត្រូវបានទទួលស្គាល់ជាកម្មករសំខាន់ចាំបាច់។*** គេមិនអាចចាត់ទុកជាកម្មករ "គ្មានជំនាញ" មិនមែនជាការងារស្ទួល ដែលត្រូវជួលពីខាងក្រៅ និងទទួលបានប្រាក់ឈ្នួលទាបទៀតទេ។ វាជាការងារមួយដែលកំណត់ថាតើសណ្ឋាគារមួយមានសុវត្ថិភាពឬគ្មាន។ ជីវិតទាំងឡាយ ត្រូវពឹងផ្អែកទៅលើការងារទាំងនោះ (ហើយវាមិនមែនជាការបំផ្លើសឡើយ នៅក្នុងសម័យកូវីដ-១៩ នេះ)។ វាជាការងារដែលមានតម្លៃ ហើយតម្លៃនេះ ត្រូវតែប្រែក្លាយទៅជាប្រាក់ឈ្នួលប្រសើរជាងមុន និងជាការងារដែលមានសុវត្ថិភាព។ មិនមានកម្រិតនៃការផ្សព្វផ្សាយអំពីម៉ាកយីហោឡើងវិញនិងវិធីសាស្ត្រវេទមន្តនៃសាជីវកម្មណាមួយ ដែលអាចផ្លាស់ប្តូរការពិតនោះបានឡើយ។